ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងមហាផ្ទៃ

លេខ: ១៣៤៧ សរ.ណ

រដ្ឋបាលខេត្តបាត់ដំបង
ចូល
លេខ: 648
ថ្ងៃទី...ខែ...ឆ្នាំ២០២០
ម៉ោង: 08:49
បញ្ជូនទៅ: ...

# ជម្រាបមក

## ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលខេត្តជាប់ព្រំដែន

**កម្មវត្ថុ** ៖ ករណីសំណើសុំជួយអន្តរាគមន៍ទប់ស្កាត់និងហាមឃាត់ការនាំចូលបន្លែ-ផ្លែឈើដែលមានជាតិគីមីពុលពីបរទេសចូលមកព្រះរាជាណាចក្រកម្ពុជា។

**យោង** ៖ លិខិតលេខ១៦៩៥កសក ចុះថ្ងៃអង្គារ ១០រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម លោកជំទាវ** ជ្រាបថា ផ្អែកតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្ញើលិខិតមកក្រសួងមហាផ្ទៃ ស្នើសុំជួយអន្តរាគមន៍ទប់ស្កាត់និងហាមឃាត់ការនាំចូលបន្លែ-ផ្លែឈើដែលមានជាតិគីមីពុលពីបរទេសចូលមកព្រះរាជាណាចក្រកម្ពុជា។ ពាក់ព័ន្ធករណីនេះ ក្រសួងមហាផ្ទៃស្នើរដ្ឋបាលខេត្តជាប់ព្រំដែន ណែនាំដល់អាជ្ញាធរមានសមត្ថកិច្ចប្រចាំច្រកទ្វារព្រំដែនទាំងអស់ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ត្រូវពង្រឹងការត្រួតពិនិត្យបន្ថែមទៀតដើម្បីទប់ស្កាត់ការនាំចូលបន្លែ-ផ្លែឈើមានជាតិគីមីពុលនិងទំនិញខូចគុណភាព សំដៅការពារអាយុជីវិតនិងសុខភាពប្រជាពលរដ្ឋ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ** ជ្រាប និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម **ឯកឧត្តម លោកជំទាវ** ទទួលនូវការរាប់អានពីខ្ញុំ។

ថ្ងៃ... ខែ... ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ ២០២០

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

ស ខេង

**ចម្លងជូន** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ឯកសារ-កាលប្បវត្តិ

ទីស្តីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ e-mail : moi@interior.gov.kh web : www.interior.gov.kh